

បញ្ហានៃការចែករំលែក

ដោយ ដន ហ៊ីយុន
(ដែលទៅលើដំណើររឿងពិត)

ក្រែប។ ក្រែប។ អាន់ន្ទ្រូបានលេបពោតលីងរបស់គាត់ហើយបានចាប់យកមួយដៃពេញទៀត ។

បងប្រុសរបស់គាត់ ខេលិប បានទម្លាក់ខ្លួនអង្គុយចុះលើសាឡុងក្បែរគាត់ ។ « ណ្ហ៎ បងសូមញ៉ាំផងបានទេ ? »

អាន់ន្ទ្រូ នៅបន្តមើលទូរទស្សន៍ ។ « អត់ទេ » ។

« អ៊ូ តិចមក ។ ឯងអាចចែកបាន » ។

ខេលិប លូកដៃទៅក្នុងចាន ប៉ុន្តែអាន់ន្ទ្រូបានអង្ករក់យកវាទៅឆ្វាយ ។

« ទេ ! ខ្ញុំបានប្រាប់ហើយ ។ កុំសូមទៀត ! »

« ក็បាន » ។ ខេលិប ដើរក្រោកឡើង ហើយដើរចេញពីបន្ទប់ ។

នៅថ្ងៃស្អែកឡើង អាន់ន្ទ្រូបានចូលទៅផ្ទះបាយ ។ ខេលិប បានធ្វើស៊ូស៊ីជាមួយនឹងបាយសារ៉ាយ និងសាច់ជ្រូកកំប៉ុង ។

អាន់ន្ទ្រូហៀរទឹកមាត់ ។ « តើខ្ញុំសូមញ៉ាំផងបានទេ ? »

ខេលិប និយាយថា « អត់ទេ » ។

ណ្ឌងនោះបានធ្វើឲ្យអាន់ន្ទ្រូខឹងយ៉ាងខ្លាំង ។ គាត់បានរត់ចុះទៅក្រោមទៅប្រាប់ប៉ា ។

គាត់សួរថា « ហេតុអ្វីបានជាខេលិបកំណាញ់ម្ល៉ះ ? »

ប៉ា ធ្វើមុខស្រពោន ។ « ប៉ាបានយើញកាលពីម្សិលមិញកូនមិនបានចែកពោតលីងរបស់កូនទេ ។ ហេតុអ្វី ខេលិបគួរតែចែកជាមួយកូនក្រោយពីកូនមិនចែកជាមួយគាត់ផងនោះ ? »

អាន់ន្ទ្រូ និយាយ « ដោយសារគាត់គឺជាបងរបស់ខ្ញុំ ! »

« អ៊ីចឹងម៉េចបានជាកូនមិនចែកជាមួយបង ? »

« គាត់មិនដែលចែកជាមួយកូនផង ! « ក្រៅពីនេះ កូនបានធ្វើវាសម្រាប់ខ្លួនកូនទេ មិនមែនសម្រាប់គាត់ឡើយ »អាន់ន្ទ្រូ និយាយ ។ ប៉ុន្តែគាត់មានអារម្មណ៍សោកស្តាយបន្តិច ។ ប្រហែលជាគាត់ចិត្តអាក្រក់មិនព្រមចែក ។

« តើកូនមានដឹងទេថា នៅប្រទេសកូរ៉ូ ការចែករំលែកមានសារៈសំខាន់ ណាស់ ? » ប៉ាបានសួរ ។ គ្រួសាររបស់អាន់ន្ទ្រូមកពីប្រទេសកូរ៉ូ ។ « ការចែករំលែក គឺជារបៀបមួយបង្ហាញដល់នរណាម្នាក់ថាយើងបារម្ភចំពោះពួកគេ ។ ដូច្នោះ បើយើងមិនចែករំលែក វាហាក់បីដូចជាថា យើងមិនបារម្ភចំពោះពួកគេទេ » ។

« ប៉ុន្តែ ខ្ញុំ ពិតជា បារម្ភចំពោះ ខេលិប » ។

អាន់ន្ទ្រូបានគិតអំពីអ្វីដែលព្រះយេស៊ូវនឹងធ្វើ ។ គាត់បានចាំពីរបៀបដែលព្រះយេស៊ូវស្រឡាញ់មនុស្សគ្រប់រូប–សូម្បីតែអ្នកដែលមិនសប្បុរសចំពោះទ្រង់ក็ដោយ ។

គាត់បានប្រាប់ប៉ាថា « កូនគិតថា កូននឹងចែកជាមួយ ខេលិបថ្ងៃស្អែក ហើយចាំមើលមានអ្វីកើតឡើង » ។

ប៉ា បានញញឹម ។ « ប៉ាគិតថា នោះជាគំនិតល្អណាស់កូន » ។

ពេលអាន់ន្ទ្រូចូលគេងនៅយប់នោះ គាត់បានគិតអំពីរឿងល្អ។ដែលគាត់អាចធ្វើឲ្យ ខេលិប ។ គាត់មានចិត្តរីករាយក្នុងការចាប់ផ្តើមចែករំលែក !

នៅថ្ងៃស្អែកឡើង អាន់ន្ទ្រូបានត្បាក់ឡើងដោយការត្បាក់ផ្អ៊ីលមួយ ។ ខេលិប បានធ្វើអាហារពេលព្រឹកសម្រាប់គាត់ !

ខេលិបនិយាយ « ប៉ាបាននិយាយជាមួយបងអំពីការចែករំលែក » ។ « បងចង់ធ្វើឲ្យបានល្អជាងមុន ។ ‹ ហេតុដូច្នោះ បងបានធ្វើអាហារពេលព្រឹកឲ្យឯង » ។

« អរគុណ ! » អាន់ន្ទ្រូនិយាយ ។ « ខ្ញុំចង់ធ្វើឲ្យបានល្អជាងមុនដែរ » ។

ក្រោយមកទៀតថ្ងៃនោះ អាន់ន្ទ្រូ និងខេលិបបានមើលតាពយន្តមួយ ។ អាន់ន្ទ្រូ បានឲ្យ ខេលិបជីសតាពយន្តមួយ ។ បន្ទាប់មកគាត់បានធ្វើពោតលីងឲ្យខេលិប ! គាត់បានមើលទៅក្នុងចាន ។ វាហាក់ដូចជាពោតលីងនោះនិយាយថា « ញ៉ាំខ្ញុំទៅ ! » ប៉ុន្តែអាន់ន្ទ្រូមិនបានយកញ៉ាំទេ ។ គាត់បានឲ្យចានពោតលីងនោះទៅខេលិប ហើយនិយាយថា « ទាំងអស់ជារបស់បង ។ ខ្ញុំសូមទោស ដែលខ្ញុំពុំបានចែកជាមួយបងកាលពីមុន » ។

អាន់ន្ទ្រូបានចែករំលែកជាមួយខេលិប ពេញមួយសប្តាហ៍ ។ គាត់បានអនុញ្ញាតឲ្យខេលិប អានសៀវភៅរបស់គាត់ ។ គាត់ បានអនុញ្ញាតឲ្យខេលិបប្រើប៊ិចរបស់គាត់ ។ គាត់បានអនុញ្ញាតឲ្យខេលិបលេងប្រដាប់ក្មេងលេងដែលគាត់ចូលចិត្ត ។ គាត់ថែមទាំងបានផ្តល់ផនបន្ថែមដល់ ខេលិបនៅពេលពួកគេកំពុងលេងហ្គេម ។

នៅពេល អាន់ន្ទ្រូ កាន់តែចែករំលែកជាមួយ ខេលិប នោះ ខេលិបកាន់តែចែករំលែកជាមួយគាត់កាន់តែច្រើនដែរ ! មិនយូរប៉ុន្មាន ពួកគេបានធ្វើរឿងល្អឲ្យគ្នាទៅវិញទៅមកគ្រប់ពេលផសា ។ អាន់ន្ទ្រូបានដឹងថា ព្រះវរបិតាសួគ៌បានកំពុងតែជួយគាត់ចេះចែករំលែកជាមួយបងប្រុសរបស់គាត់ ។ អាន់ន្ទ្រូ មិនល្អតតឡោះ ដូចជាព្រះយេស៊ូវទេ ប៉ុន្តែគាត់កំពុងព្យាយាមដើម្បីប្រែក្លាយឲ្យកាន់តែដូចទ្រង់រៀងរាល់ថ្ងៃ ។ ●

ដំណើររឿងនេះបានកើតឡើងនៅ សហរដ្ឋអាម. ។